# អនុស្សរណៈនៃការយោគយល់គ្នា
# រវាង
# រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
# និង
# រដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ
# ស្តីពី
# កិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញដូរមនុស្ស និងការជួយជនរងគ្រោះដោយសារការជួញដូរ

រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ (ដែលតទៅនេះកំណត់ថាជា "រដ្ឋភាគី")

**ដោយមានបំណង**ពង្រឹងបន្ថែមទៀតនូវចំណងមិត្តភាពរវាងប្រទេសទាំងពីរ និងបង្កើនកិច្ចសហប្រតិបត្តិការទ្វេភាគី ស្តីពីការបង្ក្រាបការជួញដូរមនុស្ស ។

**ដោយទទួលស្គាល់ថា** ការជួញដូរមនុស្សគឺជាការរំលោភបំពានសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ ហើយជាការជាន់ឈ្លីយ៉ាងធ្ងន់ទៅលើសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ។

**ដោយមានការព្រួយបារម្ភជាខ្លាំងថា** ការជួញដូរមនុស្សជះឥទ្ធិពលជាអវិជ្ជមានទៅលើការរីកចម្រើននៃសរីរាង្គបុគ្គល គំនិតស្មារតី ទឹកចិត្ត សីលធម៌ និងធ្វើឲ្យខូចប្រយោជន៍ដល់របៀបរៀបរយ និងតម្លៃនៃសង្គម។

ដោយយល់ឃើញថា ក្រុម និងអង្គការឧក្រិដ្ឋកម្មឆ្លងដែន មានការទាក់ទិនយ៉ាងសកម្មទៅនឹងការជួញដូរមនុស្ស ជាពិសេសកុមារ និងស្ត្រី ហើយឧក្រិដ្ឋកម្មដែលមានការចាត់តាំង និងមានលក្ខណៈឆ្លងដែនបែបនេះ មិនគ្រាន់តែជះឥទ្ធិពលអាក្រក់ដល់ប្រទេសថៃនិងប្រទេសកម្ពុជាប៉ុណ្ណោះទេ ថែមទាំងជះឥទ្ធិពលអាក្រក់ដល់បណ្តាប្រទេសក្នុងតំបន់ និងពិភពលោកទាំងមូល។

ដោយធ្វើការអះអាងថា រដ្ឋភាគីមានការព្រួយបារម្ភរួមគ្នាចំពោះការជួញដូរមនុស្សដែលមានលក្ខណៈឆ្លងដែន ដូចដែលបានថ្លែងនៅក្នុងសេចក្តីប្រកាសនៅទីក្រុងបាងកក ស្តីពីទេសន្តប្រវេសន៍មិនប្រក្រតីដែលបានពិភាក្សានៅក្នុងសន្និសីទអន្តរជាតិស្តីពីទេសន្តរប្រវេសន៍ "សំដៅឱ្យមានកិច្ចសហប្រតិបត្តិការតំបន់ស្តីពីទេសន្តប្រវេសន៍មិនប្រក្រតី ឬ ទេសន្តប្រវេសន៍គ្មានឯកសារត្រឹមត្រូវ" ដែលបានប្រព្រឹត្តិទៅនៅថ្ងៃទី២១ ដល់ ២៣ ខែមេសា ឆ្នាំ១៩៩៩ ក្នុងទីក្រុងបាងកក និង "សន្និសីទរដ្ឋមន្ត្រីថ្នាក់តំបន់ស្តីពីការរត់ពន្ធ និងការជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនដែលជាប់ទាក់ទង" ដែលបានប្រព្រឹត្តិធ្វើនៅកោះបាលី ប្រទេសឥណ្ឌូនេស៊ី ថ្ងៃទី២៦ ដល់ ២៨ ខែកុម្ភៈ ឆ្នាំ២០០២ សេចក្តីថ្លែងការណ៍របស់អាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ដែលត្រូវបានអនុម័តនៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ ២០០៤ នៅទីក្រុងវៀងច័ន្ទ សាធារណរដ្ឋ

ប្រជាធិបតេយ្យប្រជាមានិតឡាវ សេចក្តីថ្លែងការណ៍របស់អាស៊ានស្តីពីការការពារ និងការលើកកម្ពស់សិទ្ធិកម្មករទេសន្តប្រវេសន៍ ដែលត្រូវបានចុះហត្ថលេខានៅថ្ងៃទី១៣ ខែ មករា ឆ្នាំ២០០៧ នៅទីក្រុងសេប៊ូ ប្រទេសហ្វីលីពីន អនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការប្រឆាំងនឹងការជួញដូរមនុស្សនៅក្នុងមហាអនុតំបន់មេគង្គ ដែលត្រូវបានចុះហត្ថលេខានៅថ្ងៃទី ២៩ ខែតុលា ឆ្នាំ ២០០៤ នៅទីក្រុងយ៉ង់ហ្គូន ប្រទេសមីយ៉ាន់ម៉ា សេចក្តីថ្លែងការណ៍រួមរបស់គំនិតផ្តួចផ្តើមសម្របសម្រួលថ្នាក់រដ្ឋមន្ត្រីមហាអនុតំបន់មេគង្គប្រឆាំងនឹងអំពើជួញដូរមនុស្ស ដែលត្រូវបានចុះហត្ថលេខា នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៧ នៅទីក្រុងប៉េកាំង សាធារណរដ្ឋប្រជាមានិតចិន គោលការណ៍ណែនាំសម្រាប់ការការពារជនរងគ្រោះដោយសារការជួញដូរ នៅក្នុងមហាអនុតំបន់មេគង្គ នៅថ្ងៃទី២២ ដល់ ២៤ ខែ សីហា ឆ្នាំ ២០០៧ និងសេចក្តីថ្លែងការណ៍រួមរបស់ឧមមីតលើកទី២ នៅថ្ងៃទី១៦ ខែ កុម្ភៈ ឆ្នាំ ២០១២ ក្រុងហាណូយ សាធារណរដ្ឋសង្គមនិយមវៀតណាម។

**ដោយរំលឹកឡើងវិញ** អំពីកំណត់ហេតុដែលភាគីទាំងពីរបានព្រមព្រៀងគ្នា ក្នុងសម័យប្រជុំលើកទី៣ នៃគណៈកម្មការរួមសម្រាប់កិច្ចសហប្រតិបត្តិការទ្វេភាគីរវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ ដែលបានធ្វើឡើងនៅខេត្តសៀមរាបនៃព្រះរាជាណាចក្រកម្ពុជាកាលពីថ្ងៃទី៣១ ខែមករា ដល់ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០០ ដែលក្នុងនោះបានបញ្ជាក់ពីការបង្កើនកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ស្តីពីការបង្ក្រាបការជួញដូរមនុស្សឆ្លងដែនជាពិសេសការជួញដូរស្ត្រី និងកុមារ កំណត់ហេតុនៃកិច្ចប្រជុំនៅក្រុងបាងកក ថ្ងៃទី២៧-២៩ ខែតុលា ឆ្នាំ ២០០៥ ស្តីពីគោលការណ៍ណែនាំសម្រាប់ការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្ម គោលការណ៍ណែនាំសម្រាប់កិច្ចសហប្រតិបត្តិការរវាងកម្ពុជា និងថៃ ស្តីពីនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌនៃបទឧក្រិដ្ឋទាក់ទងនឹងការជួញដូរមនុស្សដែលបានធ្វើនៅខេត្តសៀមរាប ព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី២១ខែ កក្កដា ឆ្នាំ២០០៦ និងកំណត់ហេតុកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីលើកទី៥ នៅខេត្តសៀមរាប នៅថ្ងៃទី២៤ ដល់ ថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០១២ ស្តីពីការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នាសម្រាប់កិច្ចសហប្រតិបត្តិការនៅក្នុងការប្រើប្រាស់កម្លាំងពលកម្មរវាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងការងារនៃព្រះរាជាណាចក្រថៃ។

**ដោយយោង** មាត្រាដែលជាប់ទាក់ទងនឹងការជួញដូរមនុស្ស ដូចដែលបានចែងនៅក្នុងសេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្ស ពិធីសារអង្គការសហប្រជាជាតិស្តីពីការទប់ស្កាត់ការបង្ក្រាប និងការផ្តន្ទាទោសការជួញដូរមនុស្សជាពិសេសស្ត្រី និងកុមារ ដែលបំពេញបន្ថែមទៅលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង អនុសញ្ញាស្តីពីសិទ្ធិកុមារ ពិធីសារបន្ថែមស្តីពីការលក់ដូរកុមារ ពេស្យាចារក្រុមារ និងរូបអាសអាភាសកុមារ និងពិធីសារបន្ថែមស្តីពីការពាក់ព័ន្ធកុមារនៅក្នុងជម្លោះប្រដាប់អាវុធ អនុសញ្ញាអង្គ

ការពលកម្មអន្តរជាតិលេខ១៨២ ស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ អនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ២៩ ស្តីពីពលកម្មដោយបង្ខំ អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់រើសអើងប្រឆាំងនឹងស្ត្រី និងលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិផ្សេងទៀតដែលភាគីទាំងពីរបានផ្តល់សច្ចាប័ន ឬចូលជាសមាជិក។

**ដោយជឿជាក់ថា** ការបង្ក្រាបបទឧក្រិដ្ឋជួញដូរមនុស្ស តាមរយៈកិច្ចសហប្រតិបត្តិការទៅវិញទៅមកក្នុងការអនុវត្តន៍ច្បាប់ និងក្នុងនីតិវិធីព្រហ្មទណ្ឌ គឺជាវិធានការដ៏មានប្រសិទ្ធភាពក្នុងការធានាយុត្តិធម៌ប្រឆាំងនឹងការជួញដូរមនុស្ស។

**ដោយធ្វើការសន្យាថា** រដ្ឋភាគីនឹងធ្វើសហប្រតិបត្តិការយ៉ាងស្មោះស្ម័គ្រក្នុងការលុបបំបាត់ការជួញដូរមនុស្ស ព្រមទាំងការពារ និងជួយដល់ជនរងគ្រោះ។

បានព្រមព្រៀងគ្នាដូចតទៅ៖

## ផ្នែកទី១: វិសាលភាពនៃអនុស្សរណៈនៃការយោគយល់គ្នា

### ប្រការ១៖

អនុស្សរណៈនៃការយោគយល់នេះត្រូវអនុវត្តចំពោះការជួញដូរមនុស្ស ដូចមាននិយមន័យក្នុងប្រការ២ នៃអនុស្សរណៈនេះ។

## ផ្នែកទី២: និយមន័យ

### ប្រការ២៖

ក្នុងការអនុវត្តន៍អនុស្សរណៈនៃការយោគយល់នេះត្រូវបានកំណត់និយមន័យដូចតទៅ៖

ក. **"ការជួញដូរមនុស្ស"** មានន័យថា៖ ការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្តល់កន្លែងលាក់ខ្លួនឬការទទួលមនុស្សដោយប្រើប្រាស់មធ្យោបាយគម្រាមកំហែង ការប្រើប្រាស់កម្លាំង ឬទម្រង់ផ្សេងៗនៃការបង្ខិតបង្ខំ ការចាប់ពង្រត់ ការឆបោក ការបញ្ឆោត ការរំលោភអំណាច ឬការរំលោភលើស្ថានភាពដែលងាយរងគ្រោះ ការប្រគល់ឬទទួលប្រាក់យកកម្រៃ ឬផលប្រយោជន៍ណាមួយដើម្បីទទួលបានការយល់ព្រមពីសំណាក់បុគ្គលណាម្នាក់ ដែលមានអំណាចគ្រប់គ្រងលើបុគ្គលផ្សេងទៀតក្នុងគោលដៅដើម្បីកេងប្រវ័ញ្ច។ ការកេងប្រវ័ញ្ចមានដូចជា ការកេងប្រវ័ញ្ចលើពេស្យាកម្មជនដទៃ ឬទម្រង់ផ្សេងៗទៀតនៃការកេងប្រវ័ញ្ចផ្លូវភេទ ពលកម្ម ឬសេវាដោយបង្ខំ ទាសភាព ឬការអនុវត្តស្រដៀងគ្នានឹងទាសភាព សេវភាព ឬការដកហូតសរីរាង្គណាមួយ។

ខ. ការយល់ព្រមរបស់ជនរងគ្រោះដោយសារអំពើជួញមនុស្សទៅលើការកេងប្រវ័ញ្ច ដែលមានគោលបំណងគិតទុកជាមុនដូចមានរៀបរាប់នៅក្នុងកថា

ខណ្ឌ (ក) នៃប្រការនេះ នឹងមិនយកជាការបានទេប្រសិនបើមធ្យោបាយណាមួយដែលមានចែងនៅក្នុងកថាខណ្ឌ (ក) នេះ ត្រូវបានប្រើប្រាស់។

គ. ការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្តល់កន្លែងលាក់ខ្លួន ឬការទទួលយក កុមារក្នុងគោលដៅដើម្បីកេងប្រវ័ញ្ចនឹងត្រូវចាត់ទុកថាជា «ជនរងគ្រោះដោយសារការជួញដូរ» បើទោះបីជាករណីនេះមិនមានការប្រើប្រាស់មធ្យោបាយណាមួយដូចមានចែងនៅក្នុងកថាខណ្ឌ (ក) នៃប្រការនេះក៏ដោយ។

ឃ. «កុមារ» មានន័យថាបុគ្គលដែលមានអាយុក្រោម ១៨ឆ្នាំ។

## ផ្នែកទី៣: វិធានការទប់ស្កាត់

### ប្រការ៣៖

រដ្ឋភាគីត្រូវចាត់វិធានការកែទម្រង់ច្បាប់តាមការចាំបាច់ និងចាត់វិធានការសមស្របផ្សេងៗទៀតដើម្បីធានាថា ក្របខ័ណ្ឌច្បាប់នៅក្នុងយុត្តាធិការរៀងៗខ្លួន ស្របទៅនឹងសេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្ស ពិធីសារអង្គការសហប្រជាជាតិស្តីពីការទប់ស្កាត់ ការបង្ក្រាប និងការផ្តន្ទាទោសការជួញដូរមនុស្សជាពិសេសស្ត្រី និងកុមារ ដែលបំពេញបន្ថែមទៅលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង និងលិខិតតូបករណ៍អន្តរជាតិ និងតំបន់ពាក់ព័ន្ធការជួញដូរមនុស្សដទៃទៀត ដែលរដ្ឋភាគីទាំងពីរបានចូលជាសមាជិក។

### ប្រការ៤៖

រដ្ឋភាគីត្រូវអនុវត្តកម្មវិធីអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈនានា ដែលតម្រូវរបស់កុមារ ស្ត្រី និងបុរស ដើម្បីបង្កើនឱកាសមានមុខរបរ និងកាត់បន្ថយភាពងាយរងគ្រោះដោយសារការជួញដូរ។

### ប្រការ៥៖

រដ្ឋភាគីទាំងពីរត្រូវធ្វើការប្រឹងប្រែងដើម្បីទប់ស្កាត់ការជួញដូរមនុស្ស តាមរយៈវិធានការទប់ស្កាត់ ដូចតទៅ៖

ក. បង្កើនការផ្តល់សេវានិងកិច្ចគាំពារសង្គមដូចជា ជួយរកការងារឱ្យធ្វើ ជួយក្នុងការបង្កើតឱ្យមានចំណូល និងផ្តល់ការថែទាំសុខភាពដល់ប្រជាជនដែលងាយរងគ្រោះដោយសារការជួញដូរ។

ខ. កែលម្អកម្មវិធីអប់រំ និងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈឲ្យប្រសើរឡើង ដើម្បីបង្កើនការផ្សាភ្ជាប់ទៅនឹងការអប់រំ និងឱកាសការងារ។

គ. បង្កើនចំណេះដឹង និងការយល់ដឹងដល់សាធារណជន អំពីទេសន្តប្រវេសន៍ដោយសុវត្ថិភាព និងបញ្ហាជួញដូរមនុស្ស ជាពិសេសកុមារ និងស្ត្រីរួមមាន៖

(i) ផ្សព្វផ្សាយព័ត៌មានដល់សាធារណជន អំពីកត្តាប្រថុយប្រថាននៃទេសន្តប្រវេសន៍ និងគ្រោះថ្នាក់ ព្រមទាំងឥទ្ធិពលអវិជ្ជមានផ្សេងៗនៃការជួញដូរមនុស្ស។
(ii) គាំទ្រការបង្កើតឲ្យមានបណ្តាញការពារ និងឃ្លាំមើលសហគមន៍ ជាពិសេសនៅក្នុងតំបន់មានភាពប្រថុយប្រថានខ្ពស់។
(iii) ពង្រឹងកិច្ចសហប្រតិបត្តិការរវាងរដ្ឋភាគី និងផ្នែកឯកជននានា ដើម្បីពង្រីកតួនាទីរបស់ពួកគេនៅក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស។

## ផ្នែកទី៤: កិច្ចការពារជនរងគ្រោះដោយសារការជួញដូរមនុស្ស

**ប្រការ៦៖**

ជនដែលត្រូវគេជួញដូរត្រូវបានចាត់ទុកជាជនរងគ្រោះ ហើយមិនមែនជាអ្នករំលោភបំពាន ឬជាជនល្មើសច្បាប់អន្តោប្រវេសន៍ទេ។ ហេតុនេះ៖

ក. ជនដែលត្រូវគេជួញដូរមិនត្រូវបានចោទប្រកាន់ពីបទអន្តោប្រវេសន៍ខុសច្បាប់។
ខ. ជនដែលត្រូវគេជួញដូរ មិនត្រូវបានឃុំខ្លួននៅក្នុងមណ្ឌលឃុំឃាំងអន្តោប្រវេសន៍ក្នុងពេលរង់ចាំដំណើរការធ្វើមាតុភូមិនិវត្តន៍ជាផ្លូវការ មកកាន់ប្រទេសខ្លួនវិញនោះទេ ប៉ុន្តែពួកគេត្រូវស្ថិតនៅក្នុងការថែទាំរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (កម្ពុជា) ឬ នាយកដ្ឋានអភិវឌ្ឍន៍ និងសុខុមាលភាពសង្គម (ថៃ) ហើយនៅទីនោះការផ្តល់ជម្រក និងការការពារត្រូវបានផ្តល់ដល់ជនរងគ្រោះទៅតាមគោលនយោបាយរបស់រដ្ឋភាគីនីមួយៗ។
គ. អាជ្ញាធរពាក់ព័ន្ធត្រូវធានាសន្តិសុខដល់ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ។
ឃ. ជនរងគ្រោះត្រូវទទួលបានការគាំពារប្រកបដោយមនុស្សធម៌ និងត្រូវបានផ្តល់ឱកាសដើម្បីទាក់ទងជាមួយក្រុមគ្រួសារជិតស្និទ្ធ ដែលអនុវត្តប្រកបដោយសុវត្ថិភាព តាមរយៈដំណើរការនៃការការពារ ការធ្វើមាតុភូមិនិវត្តន៍ និងនៅក្នុងនីតិវិធីតុលាការ។
ង. ជនរងគ្រោះ ជាពិសេសកុមារ ត្រូវទទួលបានសេវា ផ្អែកលើសិទ្ធិជាមូលដ្ឋានសមស្របតាមអាយុ ឆ្លើយតបនឹងយេនឌ័រ ក្នុងអំឡុងពេលដំណើរការថែទាំបណ្តោះអាសន្ន ការធ្វើមាតុភូមិនិវត្តន៍ និងក្នុងនីតិវិធីតុលាការ។
ច. កុមារដែលស្ថិតនៅជាមួយជនរងគ្រោះ ត្រូវមានសិទ្ធិទទួលបានការការពារ ដោយយោងតាមច្បាប់ជាតិរបស់រដ្ឋភាគីនីមួយៗ។

**ប្រការ៧៖**

រដ្ឋភាគីត្រូវចាត់វិធានការសមស្របនានាដែលអាចរាប់បញ្ចូលលទាំងការកែទម្រង់ច្បាប់ និងជំនួយផ្នែកច្បាប់ ដើម្បីធានាឲ្យមានដំណោះស្រាយតាមផ្លូវច្បាប់ប្រកបដោយប្រសិទ្ធភាព ចំពោះជនរងគ្រោះដោយសារការជួញដូរដូចតទៅ៖

ក. ជនរងគ្រោះអាចប្ដឹងទាមទារមកវិញនូវទ្រព្យសម្បត្តិ និងសម្ភារៈជាប់ខ្លួនដែលគ្មានវិវាទ ហើយដែលត្រូវបានដកហូត ដោយអាជ្ញាធរពាក់ព័ន្ធ នៅដំណាក់កាលនានានៃដំណើរការផ្លូវច្បាប់។

ខ. ផលនៃបទល្មើសជួញដូរមនុស្ស នឹងត្រូវរឹបអូសរក្សាទុក ហើយត្រូវចាត់ចែងគ្រប់គ្រងទៅច្បាប់របស់ប្រទេសភាគីរៀងៗខ្លួន។

គ. ជនរងគ្រោះអាចប្ដឹងទារសំណងពីជនល្មើសនូវការខូចខាតទាំងឡាយ ដែលបង្កឡើងដោយការជួញដូរមនុស្ស។

ឃ. ជនរងគ្រោះអាចទាមទារផលកម្រៃពលកម្ម ដែលមិនទាន់បានទទួលពីជនល្មើស។

ង. ជនរងគ្រោះត្រូវទទួលបាននូវការអនុវត្តនីតិវិធីត្រឹមត្រូវតាមផ្លូវច្បាប់ សម្រាប់ការទាមទាររកភាពយុត្តិធម៌ក្នុងរឿងព្រហ្មទណ្ឌ និងការជួសជុលការខូចខាត និងដំណោះស្រាយផ្សេងៗទៀត តាមផ្លូវតុលាការ។

ច. ជនរងគ្រោះត្រូវទទួលបានព័ត៌មាននិងសេវាបកប្រែតាំងពីការទទួលពីដំបូងរហូតដល់ការធ្វើសមាហរណកម្ម។

**ប្រការ៨៖**

ទីភ្នាក់ងាររដ្ឋាភិបាលពាក់ព័ន្ធ ដោយមានកិច្ចសហប្រតិបត្តិការសមស្របជាមួយអង្គការមិនមែនរដ្ឋាភិបាល ត្រូវផ្ដល់ដល់ជនរងគ្រោះ និងសមាជិកគ្រួសារដែលជិតស្និទ្ធ ប្រសិនបើមាននូវជម្រកប្រកបដោយសុវត្ថិភាព និងការថែទាំសុខភាពដែលឆ្លើយតបនឹងយេនឌ័រ រួមទាំងការគាំទ្រផ្នែកចិត្តសាស្ត្រសង្គម សិទ្ធិទទួលបានជំនួយផ្នែកច្បាប់ និងការជួយឧបត្ថម្ភចាំបាច់ផ្សេងៗទៀត សម្រាប់កិច្ចការពារជនរងគ្រោះទាំងនោះ។

## ផ្នែកទី៥: កិច្ចសហប្រតិបត្តិការក្នុងការបង្ក្រាបអំពើជួញដូរមនុស្ស

**ប្រការ៩៖**

ភ្នាក់ងារមានសមត្ថកិច្ចអនុវត្តច្បាប់នៃប្រទេសទាំងពីរ ជាពិសេសនៅតាមព្រំដែន ត្រូវ ធ្វើការដោយមានកិច្ចសហការគ្នាជិតស្និទ្ធ ក្នុងការស្វែងរកឲ្យឃើញនូវការជួញដូរមនុស្សក្នុងស្រុក និង ឆ្លងប្រទេស។

**ប្រការ១០៖**

ក. ដំណើរការអនុវត្តច្បាប់ ត្រូវតែធ្វើឲ្យមានភាពប្រសើរឡើង ដើម្បីប្រយុទ្ធប្រឆាំង នឹង ឧក្រិដ្ឋកម្មជួញដូរមនុស្សឲ្យមានប្រសិទ្ធភាព។

ខ. ត្រូវបង្កើនការស៊ើបអង្កេត និងការចោទប្រកាន់ជនល្មើស និងក្រុមឧក្រិដ្ឋជន ទាក់ទងករណីជួញដូរមនុស្ស។

គ. រដ្ឋភាគីត្រូវរៀបចំកម្មវិធីបណ្តុះបណ្តាលជាឯកតោភាគី និងទ្វេភាគីស្តីពីការ ផ្តន្ទាទោស ច្បាប់ពាក់ព័ន្ធ និងជំនាញស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ការស៊ើបអង្កេត និងការការពារនៅក្នុងករណីជួញដូរ សម្រាប់មន្ត្រីទទួលបន្ទុកអនុវត្តច្បាប់ ឲ្យស្របតាមបទដ្ឋានអន្តរជាតិ។

**ប្រការ១១៖**

ក. រដ្ឋភាគីត្រូវជំរុញកិច្ចសហប្រតិបត្តិការទ្វេភាគី ចំពោះនីតិវិធីតុលាការប្រឆាំង នឹងការជួញមនុស្ស ដូចជាការផ្តន្ទាទោសចំពោះអ្នកជួញដូរឆ្លងដែន ដោយ អនុលោមទៅតាមសន្ធិសញ្ញាស្តីពីបត្យាប័នរវាងប្រទេសកម្ពុជា និងប្រទេសថៃ និងសន្ធិសញ្ញាអាស៊ានស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមកក្នុងការអនុវត្តច្បាប់ ព្រហ្មទណ្ឌ។

ខ. រដ្ឋភាគីត្រូវចាត់វិធានការជំនួយផ្នែកច្បាប់យ៉ាងទូលំទូលាយបំផុត ទៅវិញទៅ មកនៅក្នុងការស៊ើបអង្កេត ការផ្តន្ទាទោស ដំណើរការក្នុងផ្លូវតុលាការចំពោះ អំពើជួញដូរមនុស្ស ជាពិសេសលើកុមារ និងស្ត្រី រួមបញ្ចូលទាំងសន្ធិសញ្ញា ស្តីពីបត្យាប័នរវាងប្រទេសកម្ពុជា និងប្រទេសថៃ ដែលមានស្រាប់។

**ប្រការ១២៖**

នគរបាល នគរបាលយុត្តិធម៌ និងអាជ្ញាធរពាក់ព័ន្ធដទៃទៀតនៃប្រទេសទាំងពីរ ក្នុងករណីដែលអាចត្រូវធ្វើសហប្រតិបត្តិការលើការផ្លាស់ប្តូរព័ត៌មានទាក់ទងនឹងករណីជួញដូរមនុស្ស ដូចជាច្រកជួញដូរ ទីកន្លែងជួញដូរ អត្តសញ្ញាណអ្នកជួញដូរ បណ្តាញនៃការជួញដូរ មធ្យោបាយ វិធីសាស្ត្រនៃការជួញដូរ និងទិន្នន័យអំពីការជួញដូរមនុស្ស។

**ប្រការ១៣៖**

ក. ក្រសួង ទីភ្នាក់ងារ អង្គការ និងយន្តការរបស់ស្ថាប័នរដ្ឋាភិបាល និងស្ថាប័នមិន មែនរដ្ឋាភិបាលដែលជាប់ពាក់ព័ន្ធរបស់រដ្ឋភាគីទាំងពីរ ត្រូវធ្វើកិច្ចសហប្រតិបត្តិការដើម្បីប្រមូលព័ត៌មាន និងភស្តុតាងទាក់ទងនឹងករណីជួញដូរមនុស្ស។

ខ. ចំពោះកិច្ចសហប្រតិបត្តិការក្រៅផ្លូវការនៅក្នុងការស៊ើបអង្កេត ការទទួលបានព័ត៌មានយោងតាមកថាខណ្ឌខាងលើ ត្រូវបានផ្តល់ជូនយ៉ាងត្រឹមត្រូវដល់មន្ត្រីនគរបាលមានសមត្ថកិច្ច ការិយាល័យអន្តោប្រវេសន៍ ការិយាល័យព្រះរាជអាជ្ញា ឬដល់អាជ្ញាធរជាប់ពាក់ព័ន្ធដទៃទៀត ដែលចាត់វិធានការផ្នែកច្បាប់ចំពោះករណីជួញដូរមនុស្ស យោងតាមតួនាទីជាប់ពាក់ព័ន្ធ និងនីតិវិធីនៃប្រទេសរៀងខ្លួន ដូចជាការស្រាវជ្រាវរកជនល្មើស ការស៊ើបអង្កេតករណី និងដំណើរនីតិវិធីតុលាការដទៃទៀត។

គ. ភស្តុតាងដែលប្រើនៅក្នុងតុលាការ ត្រូវបានទទួលតាមផ្លូវការទូតយោងតាមច្បាប់ផ្សេងៗនៃរដ្ឋភាគីទាំងពីរ ប្រសិនបើរដ្ឋភាគីទាំងពីរមិនមានបង្កើតសន្ធិសញ្ញាទ្វេភាគី ឬពហុភាគី ដែលចែងអំពីនីតិវិធីផ្សេងៗសម្រាប់ជំនួយផ្នែកច្បាប់ទៅវិញទៅមកក្នុងបញ្ហាព្រហ្មទណ្ឌ។

**ប្រការ១៤៖**

ក. នគរបាល នគរបាលយុត្តិធម៌ និងអាជ្ញាធរពាក់ព័ន្ធផ្សេងៗទៀតនៃរដ្ឋភាគីត្រូវចាត់វិធានការចាំបាច់នានាដើម្បីធានាសុវត្ថិភាពដល់ជនរងគ្រោះ និងសាក្សីព្រមទាំងក្រុមគ្រួសាររបស់ពួកគេ នៅក្នុងអំឡុងពេល និងក្រោយពេលនៃដំណើរការរឿងក្តីតាមនីតិវិធីតុលាការ។

ខ. អាជ្ញាធរពាក់ព័ន្ធត្រូវផ្តល់ជំនួយគាំទ្រចាំបាច់ដើម្បីធានាថា ជនរងគ្រោះអាចចូលរួមបានពេញលេញនៅក្នុងនីតិវិធីតុលាការ បន្ទាប់ពីជនរងគ្រោះបានផ្តល់ការយល់ព្រមជាមុន និងដោយមានការគិតគូរទៅលើឧត្តមប្រយោជន៍របស់ពួកគេ។

## <u>ផ្នែកទី៦: ការធ្វើមាតុភូមិនិវត្តន៍</u>

**ប្រការ១៥៖**

ក. រៀបចំសម្របសម្រួលឱ្យមានការកំណត់អត្តសញ្ញាណនិងធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះឱ្យបានឆាប់រហ័ស។

ខ. អាជ្ញាធរទទួលបន្ទុកការធ្វើមាតុភូមិនិវត្តន៍ត្រូវប្រើប្រាស់ផ្លូវការទូត ក្នុងការទំនាក់ទំនង និងជូនព័ត៌មានជាមុនទៅភាគីម្ខាងទៀត ដើម្បីរៀបចំការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះ ជាពិសេសកុមារ និងស្ត្រី។

គ. ការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះ ជាពិសេសកុមារ និងស្ត្រី ត្រូវរៀបចំឡើង និងប្រព្រឹត្តទៅក្នុងឧត្តមប្រយោជន៍របស់ពួកគេ រួមមានការការពារសុវត្ថិភាព និងការគោរពសេចក្តីថ្លៃថ្នូររបស់ពួកគេ។

ឃ. ជនដែលត្រូវគេជួញដូរ ជាពិសេសកុមារ និងស្ត្រីទាំងឡាយដែលត្រូវបាន កំណត់អត្តសញ្ញាណជាជនរងគ្រោះដោយសារការជួញដូរ នឹងមិនត្រូវចាប់បញ្ជូនត្រឡប់ឡើយ។ ការធ្វើមាតុភូមិនិវត្តន៍នឹងត្រូវចាត់វិធានការយោងតាមប្រការខាងលើ។

**ប្រការ១៦៖**

ក. រដ្ឋភាគីនីមួយៗត្រូវបង្កើតក្រុមការងារមួយ។ ក្រុមការងាររបស់ភាគីនីមួយៗ ត្រូវមានស្ថាប័នបង្គោលដើម្បីសហការអនុវត្តសកម្មភាពរួម។

ខ. ក្រុមការងារត្រូវបង្កើតឡើង ដោយមានសមាសភាពពីអាជ្ញាធរមានសមត្ថកិច្ចនានា នៃប្រទេសនីមួយៗ និងដៃគូពាក់ព័ន្ធ។

គ. ក្រុមការងាររបស់រដ្ឋភាគីនីមួយៗ មានភារកិច្ចដូចតទៅ៖

(i) រៀបចំការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះ ជាពិសេសកុមារ និងស្ត្រី

(ii) អនុវត្តការធ្វើមាតុភូមិនិវត្តន៍ដែលរៀបចំឡើងសម្រាប់ជនរងគ្រោះ ជាពិសេសកុមារ និងស្ត្រី។

(iii) ផ្តល់កិច្ចការពារសន្តិសុខដល់ជនរងគ្រោះ ជាពិសេសកុមារ និងស្ត្រីនៅក្នុងដំណើរការធ្វើមាតុភូមិនិវត្តន៍។

(iv) ខិតខំត្រួតពិនិត្យនិងតាមដានការធ្វើសមាហរណកម្មជនរងគ្រោះដោយយកចិត្តទុកដាក់។

(v) បង្កើតបណ្តាញព័ត៌មានទាក់ទងនឹងការជួញដូរមនុស្សនៅក្នុងចំណោមអាជ្ញាធរអនុវត្តច្បាប់ជាតិ និងអន្តរជាតិ ព្រមទាំងសង្គមស៊ីវិលផង។

## ផ្នែកទី៧: សមាហរណកម្ម

**ប្រការ១៧៖**

ក. រដ្ឋភាគីត្រូវខិតខំធ្វើយ៉ាងណា ឱ្យសម្រេចបាននូវការធ្វើសមាហរណកម្មជនរងគ្រោះដោយសារការជួញដូរ ប្រកបដោយសុវត្ថិភាព និងមានប្រសិទ្ធភាព ទៅក្នុងក្រុមគ្រួសារ និងសហគមន៍ ទៅតាមករណីសមស្រប ដើម្បីពួកគេទទួលបានឡើងវិញនូវសេចក្តីថ្លៃថ្នូរ និងសុខុមាលភាព។

ខ. រដ្ឋភាគីត្រូវចាត់វិធានការសមស្របនានា ដែលឆ្លើយតបនឹងយេនឌ័រដោយផ្អែកទៅលើឧត្តមប្រយោជន៍របស់ជនរងគ្រោះ ដើម្បីសម្រេចគោលបំណងដូចតទៅ៖

(i) ជនរងគ្រោះដោយសារការជួញដូរនឹងមិនត្រូវទទួលរងនូវការប៉ះទង្គិចស្លាកស្នាមផ្លូវចិត្ត ឬការធ្វើឲ្យរងគ្រោះបន្ថែមទៀត នៅក្នុងនីតិវិធីតុលាការឡើយ។

(ii) បន្តផ្តល់ការគាំទ្រផ្នែកសង្គមកិច្ច សុខាភិបាល ចិត្តសាស្ត្រ និងការគាំទ្រចាំបាច់ផ្សេងៗទៀតដល់ជនរងគ្រោះដោយសារការជួញដូរ និងគ្រួសាររបស់ពួកគេ ជាពិសេសស្ត្រីមានផ្ទៃពោះ ជនពិការ និងអ្នកដែលឆ្លងជំងឺកាមរោគនិងមេរោគ និង/ឬជំងឺអេដស៍ផង។

(iii) ជនរងគ្រោះដោយសារការជួញដូរ ពុំត្រូវទទួលរងការរើសអើងពីសង្គម ឬការធ្វើឲ្យអាម៉ាសដោយសារស្លាកស្នាមផ្លូវចិត្តនោះឡើយ។

(iv) កុមាររងគ្រោះដែលមានវ័យត្រូវចូលសាលា ត្រូវបានធានានូវឱកាសទទួលការអប់រំដ៏សមស្រប។

**ប្រការ១៨៖**

ដើម្បីឱ្យការធ្វើសមាហរណកម្មមានប្រសិទ្ធភាព រដ្ឋភាគីត្រូវផ្តល់នូវកម្មវិធីបណ្តុះបណ្តាលជាឯកតោភាគី ឬទ្វេភាគី ដូចតទៅ៖

ក. កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈដល់ជនរងគ្រោះដោយសារការជួញដូរ ដើម្បីបង្កើនឱកាសមធ្យោបាយចិញ្ចឹមជីវិតបន្ថែម។

ខ. កម្មវិធីបណ្តុះបណ្តាលសម្រាប់អ្នកធ្វើការជាមួយជនរងគ្រោះដោយសារការជួញដូរស្តីអំពីការអភិវឌ្ឍន៍កុមារ សិទ្ធិកុមារ និងបញ្ហាយេនឌ័រទាក់ទងនឹងកុមារដោយយោងតាមបទដ្ឋានអន្តរជាតិ។

គ. កម្មវិធីបណ្តុះបណ្តាលស្តីពីការតាមដាន និងត្រួតពិនិត្យសម្រាប់អ្នកផ្តល់សេវាដល់ជនរងគ្រោះ។

## ផ្នែកទី៨: ក្រុមការងារចំរុះ

**ប្រការ១៩៖**

ក. រដ្ឋភាគី ត្រូវបង្កើតក្រុមការងារចំរុះមួយ។

ខ. ក្រុមការងាចំរុះនេះ មានសមាសភាពជាអ្នកតំណាងមានសមត្ថកិច្ចនៃរដ្ឋភាគីទាំងពីរ។

គ. ក្រុមការងារចំរុះ នឹងត្រូវជួបប្រជុំនៅពេលមានតម្រូវការចាំបាច់។ កាលបរិច្ឆេទ និងទីកន្លែងប្រជុំនឹងត្រូវសម្រេចដោយមានការឯកភាពពីរដ្ឋភាគីទាំងពីរ។

ឃ. ក្រុមការងារចំរុះ មានភារកិច្ចដូចតទៅ៖

(i) បង្កើតផែនការសកម្មភាពរួម
(ii) ពិនិត្យតាមដានការអនុវត្តផែនការសកម្មភាពរួមរៀងរាល់ឆ្នាំ និងធ្វើរបាយការណ៍ជូនគណៈកម្មការរួម សម្រាប់កិច្ចសហប្រតិបត្តិការទ្វេភាគីរវាងកម្ពុជា និងថៃ នៅក្នុងកិច្ចប្រជុំរបស់គណៈកម្មការនេះ។
(iii) ផ្តួចផ្តើមបង្កើតយុទ្ធសាស្ត្រ គោលការណ៍អនុវត្តន៍ និងក្របខណ្ឌចាំបាច់ផ្សេងៗទៀត ដើម្បីអនុវត្តអនុស្សរណៈនេះ។
(iv) លើកអនុសាសន៍សំដៅធ្វើឲ្យមានការរីកចម្រើន ដល់កិច្ចសហប្រតិបត្តិការទៅវិញទៅមក ក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស។
(v) ជំរុញការចូលរួម និងសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងផ្នែកឯកជន នៅក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ជាពិសេសកុមារ និងស្ត្រី ការកេងប្រវ័ញ្ចផ្លូវភេទនិងកម្លាំងពលកម្ម និងពលកម្មដោយបង្ខំ។
(vi) ពិនិត្យឡើងវិញនូវការអនុវត្តន៍អនុស្សរណៈ នេះរៀងរាល់០៣ឆ្នាំម្តង។

## ផ្នែកទី៩: អវសានបញ្ញត្តិ

**ប្រការ២០៖**

រដ្ឋភាគីត្រូវខិតខំដោះស្រាយវិវាទទាក់ទងនឹងការបកស្រាយ ឬការអនុវត្តអនុស្សរណៈនេះ តាមរយៈការចរចា។

អនុស្សរណៈនៃការយោគយល់នេះត្រូវចូលជាធរមានចាប់ពីកាលបរិច្ឆេទដែលរដ្ឋភាគីទាំងពីរបានចុះហត្ថលេខា។

**ប្រការ២១៖**

រដ្ឋភាគីនីមួយៗ អាចបញ្ឈប់ការអនុវត្តអនុស្សរណៈនៃការយោគយល់នេះបានគ្រប់ពេលវេលា ដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅរដ្ឋភាគីម្ខាងទៀតតាមរយៈការទូត ហើយការជូនដំណឹងនេះនឹងមានប្រសិទ្ធភាពអនុវត្តក្រោយរយៈពេល៦ខែ គិតចាប់ពីថ្ងៃដែលរដ្ឋភាគីម្ខាងទៀតបានទទួលលិខិតជូនដំណឹង។

**ប្រការ២២៖**

អនុស្សរណៈ នៃការយោគយល់នេះអាចធ្វើវិសោធនកម្មបាន ដោយមានការយល់ព្រមពីរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ។

**ប្រការ២៣៖**

អនុស្សរណៈនៃការយោគយល់គ្នានេះ ត្រូវជំនួសអនុស្សរណៈនៃការយោគយល់គ្នា ដែលរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃបានចុះហត្ថលេខា នៅថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៣ ដែលត្រូវឈប់អនុវត្តនៅពេលអនុស្សរណៈនេះចូលជាធរមាន។

សកម្មភាពឬវិធានការសហប្រតិបត្តិការមួយចំនួនដែលបានអនុវត្តក្រោមអនុស្សរណៈនៃការយោគយល់គ្នាដែលរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ បានចុះហត្ថលេខា នៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៣ នៅធរមាននៅឡើយ ហើយវាក៏ជាសកម្មភាព និងវិធានការសហប្រតិបត្តិការ ដែលអនុវត្តនៅក្នុងអនុស្សរណៈនៃការយោគយល់គ្នានេះផងដែរ។

ដើម្បីជាសក្ខីភាព ហត្ថលេខីដែលបានទទួលការអនុញ្ញាតត្រឹមត្រូវពីរាជរដ្ឋាភិបាលរៀងៗខ្លួន បានចុះហត្ថលេខាលើអនុស្សរណៈនេះ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣០ ខែតុលា ឆ្នាំ ២០១៤ ជាលាយលក្ខណ៍អក្សរ ជាពីរច្បាប់ ជាភាសាខ្មែរ ថៃ និងអង់គ្លេស អត្ថបទនីមួយៗមានតម្លៃស្មើៗគ្នា។ ក្នុងករណីមានការបកស្រាយខុសគ្នា អត្ថបទភាសាអង់គ្លេសត្រូវយកមកប្រើប្រាស់ជាឯកសារគោល។

| | |
|---|---|
| **តំណាងរាជរដ្ឋាភិបាល** | **តំណាងរាជរដ្ឋាភិបាល** |
| **នៃព្រះរាជាណាចក្រកម្ពុជា** | **នៃព្រះរាជាណាចក្រថៃ** |
| | ພ.ສ.ຕ.ວ. |
| **អ៊ិត សំហេង** | **អាឌុល សាងស៊ីងកែវ** |
| **រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** | **រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្ស** |

# MEMORANDUM OF UNDERSTANDING
# BETWEEN
# THE GOVERNMENT OF THE KINGDOM OF CAMBODIA
# AND
# THE GOVERNMENT OF THE KINGDOM OF THAILAND
# ON
# BILATERAL COOPERATION
# FOR
# ELIMINATING TRAFFICKING IN PERSONS AND PROTECTING VICTIMS OF TRAFFICKING

-----------------------------

**The Government of the Kingdom of Cambodia and the Government of the Kingdom of Thailand** (hereinafter referred to as the "Parties").

**HAVING SOUGHT** to strengthen the bonds of friendship between the two countries and to increase the bilateral cooperation on the suppression of trafficking in persons;

**RECOGNIZING** that trafficking in persons is a gross infringement of human rights and grievous trampling on the dignity of human beings;

**GRAVELY CONCERNED** that trafficking in persons has negative impact on individual physical, mental, emotional and moral development and is detrimental to the social fabric and values of the society;

**TAKING INTO ACCOUNT** that transnational criminal groups and organizations are actively involved in trafficking in persons, especially children and women, and that such transnational organized crimes have affected not only Thailand and Cambodia but also the region and the global community at large;

**CONFIRMING** that the Parties share the common concern against transnational human trafficking as addressed in the Bangkok Declaration on Irregular Migration Deliberated in the International Symposium on Migration "Towards Regional Cooperation on Irregular/ Undocumented Migration" held in Bangkok during 21-23 April 1999, and "Regional Ministerial Conference on People Smuggling, Trafficking in Persons and Related Transnational Crime" held in Bali of Indonesia during 26-28 February 2002, the ASEAN Declaration Against Trafficking in Persons Particularly Women and Children adopted in Vientiane of Lao PDR on 29 November 2004, the ASEAN Declaration on the Protection and Promotion of the Rights of Migrant Workers adopted in Cebu of Philippines on 13 January 2007, the Memorandum of

Understanding on Cooperation against Trafficking in Person in the Greater Mekong Sub-Region approved in Yangon of Myanmar on 29 October 2004, the Joint Declaration on the Coordinated Mekong Ministerial Initiative against Trafficking approved in Beijing of China on 14 December 2007, the Guiding Principles for the Protection of Victims of Trafficking in the Greater Mekong Sub-region on 22-24 August 2007 and the 2nd COMMIT Joint Declaration in Hanoi of Viet Nam on 16 February 2012;

**RECALLING** the Agreed Minutes of the Third Meeting of the Joint Commission for the Bilateral Cooperation between the Kingdom of Cambodia and the Kingdom of Thailand, in Siem Reap Province of the Kingdom of Cambodia, during 31 January – 1 February 2000 with regards to the intensification of cooperation in suppression cross border trafficking in human beings, especially in women and children, the Agreed Minutes of the Meeting on Guidelines on Repatriation and Reintegration in Bangkok of the Kingdom of Thailand on 27-29 October 2005, Guidelines for Cooperation Between Cambodia and Thailand on the Criminal Justice Process of Trafficked Related Crimes in Siem Reap Province of the Kingdom of Cambodia on July 21, 2006, and the Agreed Minutes of the Fifth Ministerial Meeting on the Implementation of the Memorandum of Understanding on Cooperation in Employment of Workers between the Ministry of Labour and Vocational Training of the Kingdom of Cambodia and the Ministry of Labour of the Kingdom of Thailand in Siem Reap on January 24-26, 2012;

**REFERRING** to relevant provisions concerning trafficking in persons as stipulated in Universal Declaration of Human Rights, the Protocol to Prevent, Suppress and Punish Trafficking in Persons, Especially Women and Children, Supplementing the United Nations Convention against Transnational Organized Crime, the Convention on the Rights of the Child, the Optional Protocols on the Sale of Children, Child Prostitution and Child Pornography and on the Involvement of Children in Armed Conflict, ILO Convention No.182 Concerning the Elimination of the Worst Forms of Child Labour, ILO Convention No. 29 on Forced Labour, the Convention on the Elimination of All Forms of Discrimination against Women and other international human rights instruments to which both Parties are party;

**CONVINCED** that suppressing the crime of trafficking in persons through mutual cooperation in law enforcement and criminal procedures is an effective measure to ensure justice against human trafficking;

**PLEDGING** that the Parties shall faithfully cooperate to eliminate trafficking in persons, and to protect and assist them;

**HAVE AGREED** as follows:

## I- SCOPE OF THIS MEMORANDUM OF UNDERSTANDING

**Article 1:**

This Memorandum of Understanding shall apply to trafficking in persons as defined in Article 2 of this Memorandum.

## II- DEFINITION

**Article 2:**

For the operational purpose of this memorandum,

(a) "Trafficking in Persons" shall mean the recruitment, transportation, transfer, harbouring or receipt of persons, by means of threat, use of force, or other forms of coercion, of abduction, of fraud, of deception, of the abuse of power or of a position of vulnerability or of the giving or receiving of payments or benefits to achieve the consent of a person having control over another person, for the purpose of exploitation. Exploitation shall include, at a minimum, the exploitation of the prostitution of others or other forms of sexual exploitation, forced labour or services, slavery or practices similar to slavery, servitude or the removal of organs;

(b) The consent of a victim of trafficking in persons to the intended exploitation set forth in subparagraph (a) of this article shall be irrelevant where any of the means set forth in subparagraph (a) have been used;

(c) A child who has been recruited, transported, transferred, or haboured for the purpose of exploitation shall be considered "as a victim of trafficking" even if this does not involve any of the means set forth in subparagraph (a) of this article; and

(d) "Child" shall mean any person under eighteen years of age.

## III- PREVENTIVE MEASURES

**Article 3:**

The Parties shall undertake necessary legal reforms and other appropriate measures to ensure that the legal frameworks in their respective jurisdictions conform with the Universal Declaration of Human Rights, the Protocol to Prevent, Suppress, and Punish Trafficking in Persons, especially Women and Children, supplementing the United Nations Convention against Transnational Organized Crime, and other international and regional instruments concerning trafficking in persons to which both Parties are party.

**Article 4:**

The Parties shall undertake educational and vocational training programs tailored for children, women and men to increase the opportunity for employment and hence reduce vulnerability to trafficking.

**Article 5:**

Both Parties shall make best efforts to prevent trafficking in persons through the following preventive measures:

(a) Increase of social services and protection such as assistance in job searching and income generating and provision of medical care to persons vulnerable to trafficking;

(b) Reform of educational and vocational training programs to improve their linkage with education and job opportunities; and

(c) Enhancement of public awareness and understanding on the issue of safe migration and trafficking in persons, especially children and women including:

(i.) Disseminate information to the public on risk factors of migration and the danger and negative impacts of trafficking in persons;

(ii.) Support the development of community protection and surveillance networks, especially in high risk areas;

(iii.) Strengthen cooperation between the Parties and the private sectors to expand their role in the fight against trafficking in persons.

## IV- PROTECTION OF TRAFFICKED PERSONS

**Article 6:**

Trafficked persons shall be considered victims, not violators or offenders of the immigration law. Therefore,

(a) Trafficked persons shall not be prosecuted for illegal entry to the country;

(b) Trafficked persons shall not be detained in an immigration detention center during the times awaiting the official repatriation process, but shall be put under the care of the Ministry of Social Affairs, Veterans and Youth Rehabilitation (Cambodia) or the Department of Social Development and Welfare (Thailand), and shelter and protection shall be provided to the victims according to the policy of each state;

(c) The relevant authorities shall ensure the security of trafficked persons and their families;

(d) Victims shall be treated humanely and provided with opportunity to communicate with their immediate families where it is safe to do so throughout the process of protection and repatriation, and the judicial proceedings;

(e) Victims, especially children, shall be provided rights based, age and gender sensitive services during the interim care, repatriation, reintegration and judicial processes; and

(f) Children accompanying victims shall be entitled to the protection in accordance with the national laws of each Party.

**Article 7:**

The Parties shall undertake appropriate measures, which may include legal reform and legal aid, to ensure the effective legal remedies to victims of trafficking as follows:

(a) Victims may claim restitution of any undisputed personal properties and belongings that have been confiscated or obtained by relevant authorities at any stage of the legal process;

(b) Proceeds of crime of trafficking shall be liable for confiscation and managed according to the laws of relevant country;
(c) Victims may claim compensation and restitution from the offender of any damages caused by trafficking in persons;
(d) Victims may claim payment for unpaid services from the offender; and
(e) Victims shall have access to the due process of law to claim for criminal justice, recovery of damages, and any other judicial remedies; and
(f) Victims shall be provided information and interpretive services from the intake process until reintegration.

**Article 8:**

The relevant Governmental agencies in cooperation with appropriate non-governmental organizations, shall provide trafficked persons and their immediate family, if any, with gender sensitive safe shelter and health care, including psycho-social support, access to legal assistance, and other imperatives for their protection.

## V- COOPERATION IN SUPPRESSION OF TRAFFICKING IN PERSONS

**Article 9:**

The law enforcement agencies in both countries, especially at the border shall work in close cooperation to uncover domestic and cross border trafficking in persons.

**Article 10:**

(a) The law enforcement process shall be streamlined so as to combat crimes of trafficking in persons effectively;
(b) The investigation and the prosecution of offenders and criminal syndicates in trafficking cases shall be intensified; and
(c) The Parties shall undertake training programs unilaterally and bilaterally concerning prosecution, the applicable legislation and skills of victim identification, investigation and protection in trafficking cases for law enforcement personnel in line with international standards.

**Article 11:**

(a) The Parties shall promote bilateral cooperation in the judicial procedure against trafficking, e.g., prosecution of transnational traffickers, extradition arrangement, mutual judicial assistance in the criminal procedures; and
(b) The Parties shall afford one another the widest measure of mutual legal assistance in investigation, prosecution and judicial proceeding in relation to trafficking in persons, especially children and women including existing arrangement on extradition.

**Article 12:**

The police, judicial police and other relevant authorities, as the case may be, in both countries shall cooperate in exchange of information concerning trafficking cases, e.g., trafficking routes,

places of trafficking, identification of traffickers, networks of trafficking, means and methods of trafficking, and data on trafficking.

**Article 13:**

(a) Relevant ministries, agencies, organizations and mechanisms of the government and non-government bodies of both Parties shall cooperate in collecting information and evidence related to human trafficking cases.
(b) For the informal cooperation in investigation, the information obtained in accordance with the above paragraph shall be duly delivered to the competent police office, immigration office, prosecutor's office, or other relevant authorities who takes legal action in the cases of trafficking in persons according to relevant roles and procedures of respective countries, e.g., searching for offenders, investigating in cases, and proceeding with any other judicial procedures.
(c) Evidence to be used in courts of law shall be obtained through diplomatic channels according to the laws of both countries unless both countries enact a relevant bilateral or multilateral treaty that stipulates alternate procedures for mutual legal assistance in criminal matters.

**Article 14:**

(a) The police, judicial police and other appropriate authorities of the relevant state shall undertake necessary measures to secure the safety of victims, witnesses and their families during and after the judicial proceedings.
(b) Relevant authorities shall provide necessary support to ensure that the victims participate to the fullest extent in any judicial proceedings with their informed consent and best interests.

## VI- REPATRIATION

**Article 15:**

(a) Developing arrangement to facilitate the rapid victim identification and repatriation of trafficked persons.
(b) The authorities in charge of repatriation shall use the diplomatic channel of communication to inform the other Party of repatriation arrangements of trafficked persons, especially children and women in advance.
(c) Repatriation of trafficked persons, especially children and women shall be arranged and conducted in their best interest with safety and dignity.
(d) Persons, especially children and women who have been identified as victims of trafficking, shall not be deported. Repatriation of victims will be undertaken in accordance with the above.

**Article 16:**

(a) Each Party shall establish a Working Group; each Working Group shall assign a Focal Point to cooperate on joint activities;

(b) The Working Group shall be composed of the competent authorities of that Party and other relevant partners;

(c) Each Working Group shall undertake the following duties:

(i.) to arrange repatriation of trafficked persons, especially children and women;

(ii.) to implement the arranged repatriation of trafficked persons, especially children and women;

(iii.) to provide security for trafficked persons, especially children and women in the repatriation process;

(iv.) to endeavour to closely monitor and follow the reintegration trafficking in persons; and

(v.) to establish informational networks concerning the practice of trafficking in persons among the national and international law enforcement authorities and relevant civil society organizations.

## VII- REINTEGRATION

**Article 17:**

(a) The Parties shall make all possible efforts towards the safe and effective integration of victims of trafficking into their families and communities, where appropriate, in order to restore their dignity and well-being.

(b) For this purpose, the Parties shall take appropriate gender sensitive measures with the best interest of the victims to attain the following objectives:

(i.) Victims of trafficking shall not suffer any further, victimization, stigmatization or dramatization in the judicial procedure;

(ii.) Continuous social, medical, psychological and other necessary support shall be provided to persons who are victims of trafficking and their families, particularly to pregnant women, people with disabilities, and those who are infected with sexually transmitted diseases and/or HIV/AIDS;

(iii.) Persons who are victims of trafficking, shall not be discriminated or stigmatized socially; and

(iv.) Child victims of school age shall be ensured appropriate educational opportunities.

**Article 18:**

The Parties, individually or jointly, shall provide the necessary training programs for the purpose of effective reintegration as follow:

(a) The vocational training program for victims of trafficking to increase opportunities of alternative means of their livelihood;

(b) Training programs to sensitize those working for victims of trafficking in regard to child development, child rights and child/gender issues in line with international standards; and

(c) Training programs for service providers on monitoring and follow-up.

## VIII- JOINT TASK FORCE

**Article 19:**

(a) The Parties shall establish the Joint Task Force.

(b) The Joint Task Force shall be comprised of competent representatives from both Parties;

(c) The Joint Task Force shall be called to meet as the need arises. The date and venue of the meeting of the Joint Task Force shall be agreed by both Parties.

(d) The Joint Task Force shall assume the following responsibilities:

(i.) To develop joint action plan;

(ii.) To monitor the progress of the joint action plan annually and report to the Joint Commission for Bilateral Cooperation between Cambodia and Thailand at its meetings;

(iii.) To initiate establishment of strategies, implementing guidelines and other necessary framework to implement this Memorandum;

(iv.) To make recommendations towards further development of the mutual cooperation against trafficking in persons;

(v.) To encourage participation of and cooperation with development partners, the civil society and the private sector in countering trafficking in persons, especially children and women, sexual and labour exploitation and forced labour; and

(vi.) To review the implementation of this Memorandum of Understanding every 3 years.

## IX- FINAL PROVISION

**Article 20:**

Parties shall endeavour to settle disputes concerning the interpretation or application of this Memorandum through negotiation.

This Memorandum of Understanding shall take effect on the date of signature by both Parties.

**Article 21:**

Either Party may terminate this Memorandum of Understanding at any time by giving written notice to the other Party through diplomatic channels, and the termination shall be effective six months after the date of receipt of such notice.

**Article 22:**

This Memorandum of Understanding may be amended upon the agreement of the Government of the Kingdom of Cambodia and the Government of the Kingdom of Thailand.

**Article 23:**

This Memorandum of Understanding shall supersede the Memorandum of Understanding signed by the Government of the Kingdom of Cambodia and the Government of the Kingdom of

Thailand on 31 May 2003, which shall be terminated upon the entry into force of this Memorandum of Understanding.

Any activities or cooperative measures undertaken under the Memorandum of Understanding signed by the Government of the Kingdom of Cambodia and the Government of the Kingdom of Thailand on 31 May 2003 shall remain in effect and shall be construed as activities or cooperative measures undertaken under this Memorandum of Understanding.

IN WITNESS WHEREOF, the undersigned, being duly authorized by their respective Governments, have signed this Memorandum of Understanding.

DONE at Phnom Penh on this 30th day of October 2014, in duplicate in the Khmer, Thai, and English languages, all texts being equally authentic. In case of any divergence of interpretation, the English text shall prevail.

**FOR**
**THE GOVERNMENT**
**OF THE KINGDOM OF CAMBODIA**

**ITH SAMHENG**
**Minister of Labour and Vocational Traning**

**FOR**
**THE GOVERNMENT**
**OF THE KINGDOM OF CAMBODIA**

Pol Gen. Adul Sang Sing Keo.

**Police General ADUL SANGSINGKEO**
**Minister of Social Development and Human Security**